01202474



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 02 / 2016
ម៉ោង (Time/Heure): 10:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>សាធារណៈ និងអសាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ១៤ ខែ មករា ឆ្នាំ ២០១៦

## សវនាការលើអង្គសេចក្តី - ថ្ងៃ ៣៥៧

រៀបចំដោយ៖ **ឯម ហ៊ាយ** និង Matthew J. McCARTHY

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន , ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN, ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ាយ, លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Travis Michael FARR, លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក ឡោ |

| |
|---|
| ជុនធី |
| សាក្សី៖ 2-TCW-894 |
| មេធាវីប្រឹក្សា៖ មឿន សុវណ្ណ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោកស្រី ពេជ ចរិយា, លោក លឿង សួភក្ត័, កញ្ញា សុក សុភ័គមណីកា, លោក វ៉ាត សុម៉ៅ, លោក លឿង សួភក្ត័, កញ្ញា Hannah KIM |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.១៦ | បញ្ចប់ម៉ោង៖ ១៦.០៩ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ០៩.២១ | បញ្ចប់ម៉ោង៖ ១០.២១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.២៣ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ១២ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.១៦ | ០៩.១៧ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.១៧ | ០៩.១៨ |
| ការផ្អាកកិច្ចដំណើរការនីតិវិធីសម្រាប់ឱ្យភាគីរៀបចំដាក់សំណើផ្ទាល់មាត់ | សហព្រះរាជអាជ្ញា | ០៩.២១ | ១០.២១ |
| សេចក្តីសម្រេចផ្ទាល់មាត់ក្នុងការឆ្លើយតបទៅនឹងអនុស្សរណៈសម្ងាត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ | សហព្រះរាជអាជ្ញា<br><br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ | ១០.២៣<br>១០.៥៥<br>១០.៣៤<br>១០.៣៧<br>១០.៤៦<br>១១.០១ | ១០.៣៤<br>១១.០០<br>១០.៣៧<br>១០.៤៦<br>១០.៥៥<br>១១.១៦ |

| | | | |
|---|---|---|---|
| សេចក្ដីសម្រេចផ្ទាល់មាត់ក្នុងការឆ្លើយតបទៅនឹងឯកសារ E372/1 | អង្គជំនុំជម្រះ | ១១.២២ | ១១.២៣ |
| ការណែនាំទៅអង្គភាពសោតទស្សន៍ | អង្គជំនុំជម្រះ | ១៣.៣៧ | ១៣.៤៨ |
| សវនាការអសាធារណៈទៅកាន់សាក្សី 2-TCW-894 | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ១៣.៤៨<br>១៥.៥៣ | ១៥.៥២<br>១៦.០២ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការសម្រាកដើម្បីអនុញ្ញាតឱ្យភាគីរៀបចំការឆ្លើយតបផ្ទាល់មាត់</u>**

នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើមួយជាបន្ទាន់ស្នើសុំឱ្យទទួលយកឯកសារ E319/39.3.1 ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងការស្តាប់សក្ខីកម្មរបស់សាក្សី 2-TCW-938 ឯកសារ (E372/1) ដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅពេលបន្ទាប់។ នៅថ្ងៃ ១៤ ខែ មករា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើមួយ (ឯកសារ E384) ដើម្បីស្នើឱ្យមានសេចក្តីសម្រេចផ្ទាល់មាត់ ទាក់ទិនទៅនឹងអនុសារណៈសម្ងាត់មួយដែលបានដាក់ជូនទៅអង្គជំនុំជម្រះ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ICIJ") ដែលពាក់ព័ន្ធទៅនឹងសវនាការអសាធារណៈ សម្រាប់សាក្សី 2-TCW-894 និង 2-TCW-938 ។ អង្គជំនុំជម្រះ នឹងផ្អាកធ្វើសវនាការចាប់ពីពេលនេះតទៅ រហូតដល់ម៉ោង ១០ ដើម្បីទុកពេលឱ្យភាគីមានឱកាសរៀបចំត្រៀមលក្ខណៈក្នុងការធ្វើសារណាផ្ទាល់មាត់ ។

**<u>ការឆ្លើយតបផ្ទាល់មាត់ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ (E384)</u>**

ក្នុងសវនាការអសាធារណៈ អង្គជំនុំជម្រះ បានស្តាប់សំអាងហេតុពីសហព្រះរាជអាជ្ញាអន្តរជាតិ និង បាន

ស្តាប់ការឆ្លើយតបរបស់ភាគីពាក់ព័ន្ធទៅនឹងឯកសារ E384 ។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា នៅក្នុងអនុស្សារណៈសម្ងាត់របស់ខ្លួនដែលបានផ្ញើទៅកាន់អង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរ-ជាតិ មិនបានផ្តល់មូលហេតុសមហេតុផលណាមួយទៅលើការធ្វើសវនាការជាអសាធារណៈ លើសាក្សី 2-TCW-894 និងសាក្សី2-TCW-938 នោះទេ លើកលែងតែវិធានការតែមួយគត់ដែលត្រូវបានប្រើប្រាស់។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ខ្លួនមិនអាចផ្តល់អនុសាសន៍អំពីមូលហេតុរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិដែលតម្រូវឱ្យមានសវនាការអសាធារណៈនោះទេ ចាប់តាំងពីពួកគេមិនបានចូលមើលសំណុំរឿងនៃការស៊ើបអង្កេតនាថ្មីៗកន្លងមក។ សហមេធាវីនាំមុខក៏បានបញ្ជាក់ផងដែរថា សវនាការអសាធារណៈ គួរត្រូវបានលើកលែង។

មេធាវីការពារក្តី នួន ជា បានលើកឡើងថា ការដាក់បង្ហាញឯកសារដ៏ច្រើនលើសលុប មកពីសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងស្ថិតនៅក្នុងស៊ើបអង្កេត បានរំលោភសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ នួន ជា ក្នុងការកាត់ក្តីប្រកបដោយយុត្តិធម៌ ក៏ប៉ុន្តែខ្លួនមិនជំទាស់ទៅនឹងសវនាការអសាធារណៈលើសាក្សី 2-TCW-894 និងសាក្សី 2-TCW-938 នោះទេ។

មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះមិនគួរស្តាប់សក្ខីកម្មសាក្សី 2-TCW-894 និងសាក្សី2-TCW-938 ជាអសាធារណៈទេ ដើម្បីឱ្យមានតម្លាភាពនោះ អង្គជំនុំជម្រះគឺជាស្ថាប័នឯករាជ្យ គួរតែបដិសេធទៅនឹងសំណើរបស់ចៅក្រមស៊ើបអន្តរជាតិ ឱ្យធ្វើសវនាការអសធារណៈ។ មេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះគួរតែធ្វើសវនាការអសធារណៈទៅ លើផ្នែកណាមួយសម្រាប់សាក្សី 2-TCW-894 និងសាក្សី2-TCW-938 តែប៉ុណ្ណោះ។

<u>**ការឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ឯកសារ** (E372/1)</u>

អង្គជំនុំជម្រះបានស្តាប់ការឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ទាក់ទិនទៅនឹងការទទួលយកឯកសារ E319/39.3.1 ដោយអនុលោមតាមវិធាន ៨៧ (៤) ។ សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ និងមេធាវីការពារក្តី នួន ជា សុទ្ធតែបានបញ្ជាក់អះអាងថា ខ្លួនមិនបានជំទាស់ទៅនឹងសំណើនេះទេ។ ដូច្នេះ អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ ទទួលយកសំណើនេះ។

<u>**សវនាការអសធារណៈ ស្តាប់សក្ខីកម្មសាក្សី** 2-TCW-894</u>

សហព្រះរាជអាជ្ញា សហមេធាវីនាំមុខ បានតាំងសំណួរទៅកាន់សាក្សី 2-TCW-894 នៅក្នុងសវនាការជាអសាធារណៈ។

New E3s

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9500 | D117/31 | 00964450-00964458; 00966985-00966993; 00965589-00965596 | Written Record of Interview of [REDACTED] | C | 00964453<br>00964452<br>00964456 | 00966988<br>00966987<br>0096691 | 00965592<br>00965591<br>00965595 |
| E3/9507 | D219/138 | 01056037-01056066; 01059269-01059302; 01123901-01123925 | Written Record of Interview of [REDACTED] | C | 01056057<br>01056074<br>01056066<br>01056055<br>01056067<br>01056058<br>01056060<br>01056061<br>01056062<br>01056053 | 01059289<br>01059306<br>01059298<br>01059287<br>01059299<br>01059290<br>01059292<br>01059294<br>01059295<br>01059282 | 01123921<br>01123938<br>01123930<br>01123919<br>01123931<br>01123922<br>01123924<br>01123926<br>01123927<br>01123914 |
| E3/9677 | D219 | 01151266<br>01136628 | Written Record of Interview of [REDACTED] | C | 01151273<br>01151281 | 01136635<br>01136643 | / |

<u>**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១៨)
- បង្គាប់ឱ្យផ្នែកសោតទស្សន៍ផ្តាច់ប្រព័ន្ធសោតទស្សន៍ សម្រាប់ផ្សាយជាសាធារណៈក្នុងការតាំងសំណួរទៅកាន់សាក្សី 2-TCW-894 ។ (១៣.៣៧)

| <u>កាលវេលាសវនាការបន្ត</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦

ក្រឡាបញ្ជី

ឯម ហ៊ិយ

ក្រឡាបញ្ជី

Matthew J. McCARTHY